TRUST REGULATOR
និយ័តករបរធនបាលកិច្ច
លេខ: ០០៩/២៤ ន.ប.ធ./ស.ស.ព.

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច

**និយ័តករបរធនបាលកិច្ច (ន.ប.ធ.)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បរធនបាល បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់ មេត្តាជ្រាបថា÷ ក្រុមហ៊ុន **ខុនថឹម & ស្ពេកត្រឹម ឯ.ក** (Quantum & Spectrum Co., LTD) និងក្រុមហ៊ុន **ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា)** **(PricewaterhouseCooper (Cambodia) Ltd.)** ទទួលបានការទទួលស្គាល់ពី **ន.ប.ធ.** ជាក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដោយបានបំពេញតាមលក្ខខណ្ឌតម្រូវគ្រប់គ្រាន់តាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យបរធនបាលកិច្ច។

បរធនបាល បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់ ដែលមានបំណងប្រើប្រាស់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច អាចទំនាក់ទំនងទៅកាន់ក្រុមហ៊ុនដែលមានឈ្មោះខាងលើ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម បរធនបាល បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

**និយ័តករបរធនបាលកិច្ច**